## មជ្ឈមណ្ឌលឯកសារកម្ពុជា

# ជម្លោះលើសេចក្តីសម្រេចប្រាក់ឧបត្ថម្ភមេធាវីលេចឡើងនូវភាពមិនប្រក្រតីផ្នែករដ្ឋបាល ក្នុងករណីសំណុំរឿង០០៤

*អាន ហាញឌុល : អ្នកប្រឹក្សាច្បាប់នៃមជ្ឈមណ្ឌលឯកសារកម្ពុជា*

*១២ សីហា ២០១៣*

*ប្រែសម្រួលដោយៈ នង ច័ន្ទមល្លិកា*

*ការចេញសេចក្តីសម្រេចថ្មីៗនេះ លើវិធានមូលនិធិ បានធ្វើឲ្យមានការខ្វែងគំនិតគ្នា រវាងក្រុមមេធាវីការពារក្តី និងប្រធានអង្គភាពគាំពារការការពារក្តីអន្តរជាតិ ផ្តល់ឱកាសកម្រចំពោះទំនុកចិត្តក្នុងការតាមដានករណីសំណុំរឿង០០៤ នៅអង្គជំនុំជម្រះវិសាមពាក្នុងតុលាការកម្ពុជា ។ ការស៊ើបអង្កេតរបស់តុលាការក្នុងករណីសំណុំរឿង០០៣ និង០០៤ ពាក់ព័ន្ធទៅនឹងទីតាំងឧក្រិដ្ឋកម្មមួយចំនួន តាមតំបន់ដាក់លាក់ក្នុងប្រទេសកម្ពុជា បានដំណើរការអស់រយៈពេល៤ឆ្នាំកន្លងមកហើយ ដោយឆ្លងកាត់តាមចៅក្រមស៊ើបអង្កេតអន្តរជាតិចំនួន៤រូបផ្សេងៗគ្នា ។ បើសិនជាធ្វើការប្រៀបធៀបទៅនឹងការស៊ើបអង្កេតរបស់តុលាការក្នុងករណ សំណុំរឿង០០២ ពាក់ព័ន្ធនឹងការធ្វើឡើងដោយសម្ងាត់ទូទាំងប្រទេស គឺចំណាយពេលអស់មិនដល់៣ឆ្នាំផង ។ សេចក្តីសម្រេចថ្មីៗនេះ ដូចនៅក្នុងករណីជាច្រើនក្នុងសំណុំ រឿង០០៣ និង០០៤ បង្ហាញភាពមិនប្រក្រតីនៅក្នុងដំណើរការនីតិវិធីតុលាការ ដោយលើក ឡើងថាមន្ត្រីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនគោរពពួកគាត់ចូលរួមក្នុងការជំនុំជម្រះ ។*

*រហូតដល់ឆ្នាំ២០១២ នៅពេលសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ ឡូរ៉ែន កាសស្ព័រ អានសម៉េត លើកឡើងនូវជនសង្ស័យចំនួន៥រូប ដើម្បីជាការរំពឹក តែមិនបញ្ជាក់ឈ្មោះក្នុងករណីសំណុំរឿង០០៣ និង០០៤ នូវសិទ្ធិមានមេធាវីការពារក្តី ទាំងសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ បដិសេធមិនទទួល ស្គាល់នូវសិទ្ធិរបស់ពួកគេមានមេធាវ់ការពារនៅក្នុងតុលាការ ទោះបីជាឈ្មោះរបស់ពួកគេត្រូវបានលាតត្រដាង និងឡោមព័ទ្ធដោយភ្នាក់ងារខាងសារព័ត៌មាន ដើម្បីធ្វើការសម្ភាសន៍ អំពីឧក្រិដ្ឋកម្មតាមផ្លូវច្បាប់យ៉ាងណាក៏ដោយ ។ ទោះបីជាយ៉ាងនេះក៏ដោយ នៅក្នុងខែឧសភាឆ្នាំនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ម៉ាក ហាមុន សម្រេចថា ដោយសារតែចៅក្រម កាសស្ព័រ អានសឹម៉េត មានការបញ្ជាក់ប្រាប់ទុកជាមុនទៅកាន់ជនសង្ស័យ នូវសិទ្ធមានមេធាវីការពារក្តី ឥឡូវនេះពួកគេ ប្រមូលផ្តុំនូវសិទ្ធការពារខ្លួនរបស់ពួកគេ ក្នុងអង្គជនុំជម្រះវិសាមញ្ញ*

ក្នុងតុលាការកម្ពុជា ដោយផ្អែកលើ វិធានផ្ទៃក្នុងទី២១(១)(ក) ដែលរួមមានសិទ្ធមានមេធាវីការពារក្តី ។

ជនសង្ស័យពីររូបក្នុងចំណោម៤រូបដែលនៅរស់ (ម្នាក់ស្លាប់នៅក្នុងខែឧសភា) បានស្នើសុំនូវអ្នកតំណាងស្របច្បាប់ ហើយក្រុមមួយតំណាងឲ្យជនសង្ស័យក្នុងករណី០០៤ ត្រូវបាន ចៅក្រម ហាមុន ទទួលស្គាល់ ជាក់ស្តែងគឺ៨ខែបន្ទាប់ពីសហមេធាវីអន្តរជាតិរបស់គាត់ ត្រូវបានតែងតាំងដោយអង្គភាពគាំពារការការពារក្តី និងលើសពី១ឆ្នាំបន្ទាប់ពីសហមេធាវីជាតិត្រូវបានតែងតាំង ។ អង្គភាពគាំពារការការពារក្តី តែងតាំងក្រុមទីពីរនៃមេធាវី ឲ្យតំណាងឲ្យជនសង្ស័យ ក្នុងករណីសំណុំរឿង០០៣ ក្នុងខែធ្នូ ឆ្នាំ២០១២ ទោះប់ជាយ៉ាងនេះក៏ ដោយមិនមានការផ្សព្វផ្សាយព័ត៌មានជាសាធារណៈណាមួយបង្ហាញពីការទទួលស្គាល់របស់សហចៅ ក្រុមស៊ើបអង្កេត ចំពោះសហមេធាវីជាតិ និងអន្តរជាតិ ។ ក្រុមទាំងពីរនេះមិនមានក្រុមណាមួយ ត្រូវបានបង្ហោះនៅលើគេហទំព័ររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានោះទេ ។

និទាឃរដូវឆ្នាំមុន ចៅក្រម ហាម៉ុន ទទួលស្គាល់មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងករណីសំណុំរឿង០០៣ និង០០៤ និងធានាថាឈានទៅកាន់សំណុំរឿងក្តី ដើម្បីសម្របសម្រួលនូវសិទ្ធរបស់កូនក្តីខ្លួនក្នុងការចូលរួមការស៊ើបអង្កេតរបស់តុលាការ ។ គួរបញ្ជាក់ថាមិនមានដំណើរការមេធាវីការពារក្តីរូបណា នៅក្នុងករណីនេះស្រដៀងគ្នានោះទេ ទោះបីជាមានការស្នើសុំដដែលៗក៏ដោយ ។ ស្ថិតនៅក្រោមវិធានផ្ទៃក្នុងរបស់តុលាការ មេធាវីការពារក្តីមានសិទ្ធិចូលមើលសំណុំរឿង នៅពេលដែលកូនក្តីរបស់ខ្លួនត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មណាមួយដោយ សហចៅក្រមស៊ើបអង្កេត ។ នៅក្នុងសំណុំរឿង០០១ និង០០២ សហចៅក្រមស៊ើបអង្កេត ដែលបានធ្វើការចោទប្រកាន់ជនជាប់ចោទ រង់ចាំអស់រយៈពេលជាច្រើនខែ ទម្រាំទទួលនូវលិខិតសម្រេច ពីសហព្រះរាជអាជ្ញា និងបន្ទាប់មកទៀត បន្តការស៊ើបអង្កេត ដែលចូលរួមដោយក្រុមមេធាវីការពារក្តីតាមដាននូវសំណុំករណីរឿងនេះ ។ ផ្ទុយទៅវិញ នៅក្នុងករណីសំណុំរឿង០០៣ និង០០៤ ឈ្មោះជនចោទដែលលើកឡើងដោយ សហព្រះរាជអាជ្ញាក្នុងការចាប់ផ្តើមធ្វើការអង្កេតលើកដំបូងរបស់គេនៅតែមានមន្ទិលសង្ស័យ ទោះជាចំណាយអស់រយៈពេល៤ឆ្នាំ បន្ទាប់ពីតុលាការចាប់ផ្តើមធ្វើការស៊ើបអង្កេត ។ ទោះជាយ៉ាងនេះក៏ដោយ ក្រុមមេធាវីការពារក្តីរបស់ជនជាប់សង្ស័យនឹងតាមដានការស៊ើបអង្កេតដំបូង ខុសគ្នារវាងការស៊ើបអង្កេតដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ។

ខែ មិថុនា ចៅក្រមក្នុងអង្គបុរេជំនុំជម្រះ ដើរតួជាចៅក្រមកិច្ចការរដ្ឋបាលនៃអង្គការសហប្រជាជាតិ ធ្វើទទួលស្គាល់ អង្គភាពគាំពារការការពារក្តី ដែលបដិសេធទៅនឹងការដកមូលនិធិមកវិញលើថ្លៃសំបុត្រយន្តហោះរបស់ទីប្រឹក្សាចាប់ខាងមេធាវីការពារក្តី ក្នុងការហោះហើរពីអាកាសយាន្តដ្ឋានអន្តរជាតិភ្នំពេញ ទៅកាន់ការិយាល័យសហមេធាវីអន្តរជាតិក្នុងប្រទេសហូឡង់ ចំពោះសំណារឿង ០០៤ ។ ចំពោះវិធានរបស់គាត់ ចៅក្រមទទួលបន្ទុកកិច្ចការរដ្ឋបាលនៃអង្គការសហប្រជាជាតិស្តីបន្ទោសអង្គភាពគាំពារការការពារក្តី ចំពោះភាពបរាជ័យ ក្នុងការប្រតិបត្តតាមការទាមទារតាមផ្លូវយុត្តាធិការដែលអាចអនុវត្តបាន និងស៊ើបអង្កេតវិធានមូលដ្ឋាននៃយុត្តិធម៌ទូទៅ ឬធ្វើតាមដំណើរការនីតិវិធីត្រឹមត្រូវ ឬយកចិត្តទុកដាក់លើសិទ្ធទាំងអស់ពាក់ព័ន្ធនឹងជនសង្ស័យ នៅក្នុងដំណើរការនីតិវិធី ។

យោងទៅតាម ចៅក្រមទទួលបន្ទុកកិច្ចការរដ្ឋបាលរបស់អង្គការសហប្រជាជាតិ ជំនួសឲ្យការវាយតម្លៃថាតើ ការហោះហើរមាន “ភាពចាំបាច់ និងសមហេតុផលដែរទេ សម្រាប់ការផ្តល់ជាប្រឹក្សាដ៏មានប្រសិទ្ធិភាព និងជាតំណាងឲ្យជនជាប់សង្ស័យ” បន្ទាប់មកទៀតធ្វើការកំណត់ចំនួនទឹកប្រាក់អាចចំណាយបាននៅក្នុងកញ្ចប់ថវិកា បែរជាអង្គភាពគាំពារការការពារក្តី បដិសេធទាំងជំហរលើមូលធនហិរញ្ញវត្ថុដោយពុំបានដឹង ឬធ្វើការស៊ើបសួរថាតើមានមូលនិធិដែលអាចប្រើប្រាស់បានដែរឬទេ ។ លើសពីនេះទៅទៀត ឆ្លងតាមដំណាក់កាលនៃការសម្រេចចិត្ត តម្រូវការដើម្បីជួយសម្រួលដល់ការការពារក្តីចំពោះជនជាប់សង្ស័យ គឺ “មិនមានភាពគ្រប់គ្រាន់ ឬមិនសមរម្យលើការពិចារណាឲ្យបានត្រឹមត្រូវ” ហើយសិទ្ធរបស់គាត់ថែមទាំងត្រូវបាន “មើលស្រាល” ដោយអះអាងថា គាត់ពុំត្រូវបានក្លាយជា “ជនដែលត្រូវចោទប្រកាន់” នៅឡើយទេ ។ ទោះបីជាយ៉ាងនេះក៏ដោយ “នៅពេលធ្វើការដោះស្រាយបញ្ហាដែលពាក់ព័ន្ធ យ៉ាងហោចណាស់គណៈកម្មការជនសង្ស័យលើឧក្រិដ្ឋកម្មដ៏សាហាវយង់ឃ្នងទៅកាន់មនុស្សទូទៅ សិទពាក់ព័ន្ធសមរម្យរបស់ពួកគេគឺមានភាពចាំបាច់បំផុត” ។

អ្វីដែលគួរឲ្យកត់សម្គាល់លើសពីនេះទៀតនោះ ចៅក្រមទទួលបន្ទុកកិច្ចការរដ្ឋបាលអង្គការសហប្រជាជាតិ រកឃើញថា អង្គភាពគាំពារការការពារក្តី គឺបានដាក់នូវសំណើរទិសដៅមូលនិធិហួសហេតុពេក ដែលរំលោភបំពានលើក្រុមករណីសំណុំរឿង០០៤ ជាងការស្នើសុំនៅក្នុងសំណុំរឿង០០១ និង០០២ ហើយនៅតែមានភាពតានតឹងៈ

> ចៅក្រមទទួលបន្ទុកកិច្ចការរដ្ឋបាលអង្គការសហប្រជាជាតិ ធ្វើការអង្កេតចំពោះអង្គភាពគាំពារការការក្តី...ថាទំនងផ្សារភ្ជាប់នូវដំណើរការសម្រេចចិត្តចំពោះវិសោធនកម្ម ដើម្បីណែនាំនៅក្នុងបរិបទ មិនបើកចំហរ បដាក់បន្ទុកដល់ម្ចាស់ដើមបណ្តឹងនៅក្នុងស្ថានភាពចាញ់ប្រៀប

បើសិនជាធ្វើការប្រៀបធៀបទៅនឹងក្រុមមេធាវីការពារក្តីផ្សេងទៀត និងដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគេនៅក្នុងករណីសំណុំរឿង០០១ និង០០២ ខណៈពេលដែលពួកគេកំពុងបំពេញ នូវសំណុំលិខិតកិច្ចសន្យា ស្របពេលជាមួយនឹងដំណើរការនីតិវិធី ហើយដូចដែលបេក្ខជនដែលឥឡូវនេះ...ការផ្លាស់ប្តូរនូវគោលការណ៍មួយចំនួនបានបញ្ជាក់ឲ្យឃើញច្បាស់ អំពីការដាក់បញ្ចូននូវប្រធានបទទាំងនោះនៅក្នុងការស៊ើបអង្កេតករណីសំណុំរឿង០០៤ នឹងធ្វើឲ្យខូចប្រយោជន៍ បើសិនជាធ្វើការប្រៀបធៀបទៅប្រធានបទមួយចំនួនដែលដាក់បញ្ចូននៅក្នុងការស៊ើបអង្កេតក្នុងករណីសំណុំរឿង០០១ និង០០២ អាស្រ័យហេតុដូចនេះ នឹងធ្វើឲ្យមានការរំលោភបំពានលើគោលការណ៍ស្មើភាពគ្នា មុនពេលដែលមានការអនុវត្តតាមផ្លូវច្បាប់ ។

យោងតាមក្រុមមេធាវីការពារក្តីរបស់ជនជាប់សង្ស័យ ចៅក្រម ដននីង ដែលជាអ្នកបង្កើតវិធានក្នុងអង្គបុរេជំនុំជម្រះ និងសង្កត់ធ្ងន់លើការភ្ជាំងភ្ជាត់ជាអាទភាព ក្នុងកិច្ចការរដ្ឋបាលចំពោះករណី០០៣ និង០០៤ បញ្ជាឲ្យមានការផ្សព្វផ្សាយជាសាធារណៈចំពោះសេចក្តីសម្រេចរបស់ចៅក្រមទទួលបន្ទុកកិច្ចការរដ្ឋបាលអង្គការសហប្រជាជាតិធ្វើឡើងនៅខែមុនៗ ជាក់ស្តែង ព័ត៌មានជាសាធារណៈតិចតួចដែលអាចរកបាន កំពុងបន្តជិនះលើឧបសគ្គនេះ ដើម្បីឈានដល់ដំណើរការនីតិវិធីសំណុំរឿងទាំងនេះ ដោយគោរពតាមវិធានច្បាប់ និងការអនុវត្តជាអាទិភាព។ តុលាការបានបញ្ជាក់ថាមិនមានព័ត៌មានបន្ថែមទេ ដែលពន្យល់ពីមូលហេតុនៃការស៊ើបអង្កេតដែលបន្សល់ទុកនូវការស៊ើបអង្កេតមិនពេញលេញ និងពុំមានជនជាប់សង្ស័យណាត្រូវបានចោទប្រកាន់នៅឡើយទេ ។